លេខ ១០៤៨ ក.យ.ធ ភ្នំពេញ, ថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៨២

# សារាចរ

## រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ជំរាបមក

- សមមិត្ត អនុប្រធាន ចៅក្រម នៃតុលាការប្រជាជន ខេត្ត-ក្រុង

- សមមិត្តរដ្ឋអាជ្ញា អមតុលាការប្រជាជន ខេត្ត-ក្រុង

**កម្មវត្ថុ** ៖ សេចក្តីណែនាំអំពីនីតិវិធីព្រហ្មទណ្ឌ និង របៀបចាត់ការ សំរាប់ អយ្យការ និង តុលាការប្រជាជន ខេត្ត-ក្រុង។

ក្រសួងយុត្តិធម៌យល់ឃើញថា នៅពេលបំពេញការងារខាងមុខ អ្នកទទួល ខុសត្រូវផ្នែកខាងអយ្យការ ឬ ផ្នែកខាងតុលាកា ច្បាស់ជាជួបនឹងការលំបាកអ្វី ខាន។ ប្រសិនបើ ការលំបាកនោះ មិនត្រូវបានដោះស្រាយ ដោយវិធីជាវិជ្ជមានមួយទេ ផលវិបាក អាចនឹងធ្វើឱ្យប៉ះពាល់ដល់នីត្យានុកូលភាព ដល់ផលប្រយោជន៍ សង្គម និង ពលរដ្ឋ ព្រមទាំងធ្វើឱ្យប៉ះពាល់ ដល់នយោបាយ របស់រដ្ឋទៀតផង។

ដូចនេះ ដើម្បីបង្ការនូវគ្រប់យថាហេតុ និង ដើម្បីណែនាំអ្នកទទួលខុស ត្រូវខាងផ្នែកនេះ ដែលទើបតែងតាំងថ្មីមួយមានលទ្ធភាពបំពេញការងារបានល្អ ក្រសួងយុត្តិធម៌ មានកាតព្វកិច្ច ធ្វើសេចក្តីណែនាំដោយសង្ខេបអំពីនីតិវិធី និង របៀបចាត់ការរបស់អយ្យការ និង តុលការ។

សេចក្តីណែននេះមានពីរផ្នែក ផ្នែកទី១ ស្តីពីនីតិវិធី និង របៀបចាត់ ការរបស់អយ្យការ ផ្នែកទី ២ ស្តីពីនីតិវិធី និង របៀបចាត់ការរបស់តុលាការ មុនពេលជំនុំជំរះ និង នៅពេលជំនុំជំរះ។

### I - អំពីនីតិវិធី និង របៀបចាត់ការរបស់អយ្យការ

ក្រោយពីបានទទួលសំណុំរឿងពីអង្គការស៊ើបអង្កេតហើយ រដ្ឋអ ាជ្ញមាន កាតព្វកិច្ចពិនិត្យ ពិចារណា ឱយបានហ្មត់ចត់ ទាំងខ្លឹមសារ ទាំងទម្រង់ ន សំណុំរឿង។

### ១ - ការពិនិត្យ ពិចារណាអំពីខ្លឹមសារនៃសំណុំរឿង

ការពិនិត្យ ពិចារណាអំពីខ្លឹមសារ នៃសំណុំរឿង មានសារៈសំខាន់ណាស់ ពីព្រោះខ្លឹមសារនេះ អាចឆ្លុះបញ្ចាំងបានអំពីលក្ខណៈពិតប្រាកដ របស់រឿងនីមួយៗ ថាជារឿងមានលក្ខណៈ រដ្ឋប្បវេណី ឬ ជាព្រហ្មទណ្ឌ ធ្ងន់ ឬ ស្រាល និង អាចឱ្យប្រមាណបានអំពីភាពអន្តរាយដល់គូភាគី ដល់សង្គម ដល់នយោបាយ របស់រដ្ឋ ដែលបណ្តាលមកអំពីអំពើប្រព្រឹត្តខុសច្បាប់។

ប្រសិនបើរឿងមានក្ខណៈជារឿងរដ្ឋប្បវេណី រដ្ឋអាជ្ញា ត្រូវលើកលែងចោទ ប្រកាន់ ហើយត្រូវដោះលែងជនជាប់ចោទជាបន្ទាន់ បើជន់នោះ ត្រូវបានចាប់ឃុំខ្លួន។ ក្នុងករណីនេះ រដ្ឋអាជ្ញាត្រូវឱយដំណឹងដល់ដើមបណ្តឹង ឬ ក៏បញ្ជូនសំណុំ រឿងនោះទៅតុលាការផ្នែករដ្ឋប្បវេណី ដែលជាតុលាការមានសមត្ថកិច្ច។ ក្នុងការពិនិត្យ ពិចារណាអំពីខ្លឹមសារនៃសំណុំរឿងរដ្ឋអាជ្ញា ត្រូវ ផ្តោតទៅលើល័ក្ខខ័ណ្ឌ ដូចតទៅ៖

- សំណុំរឿង មានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ គ្រប់គ្រាន់ហើយឬនៅ

- ការកំណត់ឈ្មោះបទល្មើស និង បញ្ញត្តិច្បាប់ ដែលសំអាង ដើម្បីផ្តន្ទាទោស

- អំពីស្ថានភាពនៃជនជាប់ឃុំឃាំង តើគួរអនុញ្ញាត ឱ្យនៅកឃុំបណ្តោះអាសន្ន ឬ គួរឃុំបន្តទៅទៀត

- ការប៉ាន់ប្រមាណអំពីភាពអន្តរាយអំពីទ្រព្យសម្បត្តិរបស់ជនជាប់ចោទ និង វិធានការ ដែលត្រូវចាត់ទៅលើវត្ថុតាងដែលរឹបអូសបាន។

**ក - សំណុំរឿង មានលក្ខណៈជាបទល្មើសព្រហ្មទណ្ឌ គ្រប់គ្រាន់ហើយ ឬនៅ**

ក្នុងចំណុចនេះ អយ្យការ ត្រូវពិនិត្យមើលលិខិតក្នុងសំណុំរឿង ឱ្យបានល្អិតល្អន់ ដើម្បីឱ្យដឹងថា មានភស្តុតាងគ្រប់គ្រាន់ហើយ ឬ នៅ ចំពោះរឿង ដែលមានភស្តុតាងជាស្នា កសាមលើជនរងគ្រោះ ត្រូវពិនិត្យឱ្យបានហ្មត់ចត់ នូវកំណត់ហេតុ ស្លាកស្នាម ឧបករណ៍ ដោយប្រៀបធៀបនឹងឯកសារផ្សេងៗទៀត។ ប្រសិនបើរឿងស្តីពីការកេងប្រវ័ញ្ចន៍យកទ្រព្យសម្បត្តិរដ្ឋ ពីសំណាក់ អ្នកកាន់រដ្ឋអំណាចណាមួយនោះ ត្រូវយកចិត្តទុកដាក់ពិនិត្យមើល តើក្នុងសំណុំ រឿងនោះ មានសំបុត្រស្នាម បញ្ជីសៀវភៅ និង ឯកសារចាំបាច់ សំរាប់បញ្ជាក់ អំពីការកេងប្រវ័ញ្ចន៍នោះហើយឬនៅ។

ប្រសិនបើ នៅពេលពិនិត្យសំណុំលិខិតនោះ រដ្ឋអាជ្ញាយល់ឃើញថាមានការខ្វះចន្លោះដែលជាហេតុធ្វើឱ្យសំណុំរឿងមានលក្ខណៈមិនគ្រប់គ្រាន់រដ្ឋអាជ្ញា អាចបង្វិលសំណុំរឿងនោះ ទៅអង្គការស៊ើបអង្កេត ដើម្បីធ្វើការអង្កេតស៊ើបសួរបន្ថែម ឬ ក៏ចុះផ្ទាល់ធ្វើការអង្កេតស៊ើបសួរបន្ថែម បើយល់ឃើញថាជាការចាំបាច់។

**ខ - ការកំណត់ឈ្មោះបទល្មើស និង បញ្ញត្តិច្បាប់ ដែលសំអាងដើម្បីផ្តន្ទាទោស**

ឆ្លងតាមរយៈការពិនិត្យលិខិតក្នុងសំណុំរឿង រដ្ឋអាជ្ញា ត្រូពិចារណាឱ្យ ហ្មត់ចត់ថា តើខ្លឹមសារនៃរឿងមានភាពគ្រប់គ្រាន់ អាចឱ្យសន្និដ្ឋានបាន ថាមានបទល្មើសឬទេ? ប្រសិនបើមាន តើជាបទល្មើសអ្វី ហើយបទល្មើស ត្រូវផ្តន្ទាទោសតាមបញ្ញត្តិច្បាប់ណា? ក្រោយពីការកំណត់បាននូវ លក្ខណៈនេះហើយ រដ្ឋអាជ្ញាត្រូវពិនិត្យលើរបាយការណ៍របស់អង្គការស៊ើបអង្កេតដើម្បីឱ្យដឹងថា របាយការណ៍នេះ មានខ្លឹមសារឆ្លើយតបនឹងលក្ខណៈ របស់រឿងឬទេ? ការចង្អុលមាត្រា ចំណុចច្បាប់ ដែលត្រូវផ្តន្ទាទោសលើ បទល្មើល តើមានភាពត្រឹមត្រូវ ឬ មិនត្រឹមត្រូវ ។

**គ - អំពីស្ថានភាពនៃជនជាប់ឃុំឃាំង តើគួរអនុញ្ញាតឱ្យ នៅក្រៅឃុំបណ្តោះអាសន្ន ឬ គួរឃុំបន្តទៅទៀត**

ប្រសិនបើនៅក្នុងសំណុំរឿង មានការឃុំខ្លួនជនប្រព្រឹត្តបទល្មើស រដ្ឋអាជ្ញា ត្រូវពិចារណាថា តើជនជាប់ឃុំឃាំង អាចឱ្យនៅក្រៅឃុំបណ្តោះអាសន្នសិនបាន ឬទេ ឬ ក៏ទុកឱ្យជននោះ នៅជាប់ឃុំបន្តទៅទៀត។ ដើម្បីពិចារណា អំពីហេតុការណ៍នេះ រដ្ឋអាជ្ញា គប្បីផ្អែកលើលក្ខណៈនៃបទល្មើស និង ស្ថានភាព ផ្ទាល់ខ្លួនរបស់ជនជាប់ឃុំឃាំង។ ប្រសិនបើបទល្មើសនោះស្រាល ជនជាប់ឃុំឃាំងមានទីលំនៅពិតប្រាកដ ព្រមទាំងជាជនទើបបានប្រព្រឹត្តកំហុសជាលើកដំបូងផងនោះ រដ្ឋអាជ្ញា អាចអនុញ្ញតឱ្យជនជាប់ឃុំឃាំង នៅក្រៅឃុំបណ្តោះអាសន្នបានទម្រាំតុលាការយករឿងជននេះ ទៅជំនុំជំរះ។ ប្រសិនបើបទល្មើសនោះ ជាបទល្មើសព្រហ្មទណ្ឌ

ដែលគ្រាន់តែត្រូវផ្តន្ទាទោសពិន័យជា ប្រាក់ប៉ុណ្ណោះ រដ្ឋអាជ្ញា ត្រូវដោះលែងជនជាប់ចោទជាបន្ទាន់ បើជននោះត្រូវបានចាប់ឃុំខ្លួន។ រីឯសំណុំរឿង ត្រូវជូនទៅតុលាការ ដើម្បីជំនុំជំរះ។

**ឃ - ការប៉ាន់ប្រមាណអំពីភាពអន្តរាយ អំពីទ្រព្យសម្បត្តិ របស់ជនជាប់ចោទ និង វិធានការ ដែលត្រូវចាត់ទៅលើវត្ថុតាងដែលរឹបអូសបាន**

នៅក្នុងចំណុចនេះ រដ្ឋអាជ្ញា គប្បីប៉ាន់ប្រមាណអំពីទ្រព្យសម្បត្តិ របស់ជនជាប់ចោទ ដែលត្រូវរឹបអូសជាបណ្តោះអាសន្ន និង ពិចារណាអំពីវិធានការ ដែលត្រូវចាត់ទៅលើវត្ថុតាង ដែលរឹបអូសបាន ថាបើជនជាប់ចោទត្រូវតុលាការ ផ្តន្ទាទោស តើទ្រព្យសម្បត្តិនេះ អាចធានាបានគ្រប់គ្រាន់ ដល់ការសងសំណង ឬ ជម្ងឺចិត្តដល់អ្នករងគ្រោះ បានឬទេ? តើវត្ថុតាង ត្រូវរឹបអូសជារបស់រដ្ឋ ឬ ត្រូវបំផ្លាញចោល? ក្នុងករណីដែលជនល្មើសមិនត្រូវចោទប្រកាន់ ឬ ត្រូវលើកលែងចោទប្រកាន់វិញ ទ្រព្យសម្បត្តិ វត្ថុតាង ដែលរឹបអូសបាននោះ តើត្រូវប្រគល់ឱ្យម្ចាស់វិញ ឬ ដូចម្តេច?។

ឧទាហរណ៍បន្ថែម៖ ដើម្បីអាចយល់ច្បាស់អំពីការសិក្សាខ្លឹមសារ នៃសំណុំរឿង គប្បីលើកឧទាហរណ៍អំពីរឿង "ធ្វើមនុស្សឃាត" មកសិក្សា។ ចំពោះរឿងនេះ រដ្ឋអាជ្ញា គប្បីពិនិត្យ ជាបឋមលើលិខិតកោសលវិច័យ ពីព្រោះ លិខិតនេះ អាចប្រាប់អំពីស្ថានភាព នៃជនរងគ្រោះស្លាប់ ពីកន្លែងនៃស្នាមរបួស។ពីសភាពនៃរបួស ពីឧបករណ៍ ដែលអ្នកប្រព្រឹត្តល្មើសយកមកប្រើ។ ទ្បាប់មក គប្បីពិនិត្យអំពីភ័ស្តុតាង អំពីកំណត់ហេតុលើកដំបូងរបស់អាជ្ញាធរមូលដ្ឋាន នៅកន្លែងកើតហេតុ រួចពិនិត្យលិខិតផ្សេងៗ ទៀត តាមលំដាប់លំដោយមាន ចម្លើយរបស់សាក្សីគ្រប់ផ្នែក សាក្សីរបស់ជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី សាក្សីរបស់ជនជាប់ចោទ ចម្លើយរបស់ជនជាប់ចោទ ចម្លើយជនរងគ្រោះ ឬ ដើមបណ្តឹងរដ្ឋប្បវេណី។ ការពិនិត្យលិខិតផ្សេងៗនេះ បង្កលក្ខណៈឱ្យដឹងថា ចម្លើយរបស់សាក្សី ឆ្លើយស្របគ្នាទៅវិញទៅមក ឬទេ អាចដៅបញ្ជាក់ឱ្យដឹងនូវលក្ខណៈរបស់រឿង ឬទេ បើប្រៀបធៀបជាមួយជនជាប់ចោទ និង ស្នាមរបួស នៃអ្នករងគ្រោះ។ ប្រសិនបើការពិនិត្យសំណុំលិខិតខាងលើនេះ មានការខ្វែងគ្នាខ្លះ ប៉ុន្តែ នៅមានលក្ខណៈ អាចទាញសេចក្តីសន្និដ្ឋានត្រឹមត្រូវមួយបានអំពីអំពើល្មើស រដ្ឋអាជ្ញា ត្រូវពិនិត្យលើលិខិតសន្និដ្ឋានរបស់អង្គការស៊ើបអង្កេត ដើម្បីឱ្យ ដឹងថា លិខិតនេះ មានខ្លឹមសារឆ្លើយតបនឹងលក្ខណៈរបស់រឿងឬទេ។ ធ្វើដូចនេះ អយ្យការ គប្បីចុះទៅពិនិត្យដល់ទីកន្លែងកើតហេតុ សួរយកព័ត៌មានពីអ្នកស៊ើបសួរលើកដំបូង ប្រសិនបើចាំបាច់ ហើយត្រូវទៅសួរយកចម្លើយពីជនប្រព្រឹត្តបទល្មើសនៅមន្ទីរឃុំឃាំង ដើម្បីពិនិត្យពីនីត្យានុកូលភាព និង អាកប្បកិរិយា របស់ជនប្រព្រឹត្តបទល្មើសនោះ។

## ២ - ការសិក្សាអំពីទម្រង់នៃសំណុំរឿង

ទម្រង់ និង ខ្លឹមសារ នៃសំណុំរឿងនីមួយៗ មានភាពទាក់ទងគ្នា។ ដូចនេះ រដ្ឋអាជ្ញា ក្រោយពីបានពិនិត្យសិក្សាអំពីខ្លឹមសារនៃរឿងហើយ ត្រូវពិនិត្យអំពីទម្រង់ នៃសំណុំរឿងជាបន្តទៅទៀត។ ប្រសិនបើរឿងណាមួយ មានមនុស្សឃុំខ្លួន ត្រូវមានលិខិតឃុំខ្លួនជាចាំបាច់ បើរឿងជាប់ទាក់ទងនឹងរឿងមនុស្សឃាត ត្រូវមានលិខិតកោសលវិច័យ លិខិតបញ្ជាក់អំពីមរណភាពនៃអ្នករងគ្រោះ។ ក្នុងសំណុំរឿង មានប្រវត្តិរូបជនជាប់ចោទគ្រប់គ្រាន់ហើយឬនៅ។ កំណត់ហេតុរបស់អង្គការស៊ើបអង្កេត មានចុះហត្ថលេខា ពីអ្នកទទួលខុសត្រូវ ក្នុងការស៊ើបអង្កេត ឬទេ មានចុះហត្ថលេខា ឬ ស្នាមមេដៃ របស់ជនជាប់ចោទ រងគ្រោះ សាក្សី ឬទេ? តើក្នុងសំណុំរឿង មានកំណត់ហេតុ ស្តីពីការកត់ត្រានូវទ្រព្យសម្បត្តិ របស់ជនប្រព្រឹត្តបទល្មើសត្រឹមត្រូវឬទេ?

ក្រោយពីបានពិនិត្យសិក្សាអំពីខ្លឹមសារ និង ទម្រង់នៃសំណុំរឿង ព្រមទាំង របាយការណ៍ របស់អង្គការស៊ើបអង្កេត ឃើញថាត្រឹមត្រូវហើយ អយ្យការ ត្រូវចុះទៅសួរជនជាប់ចោទជាលើកទី២ ដើម្បីបានយល់ច្បាស់នូវរឿងហេតុ ដែល កើតឡើង និង បានពិនិត្យមើលអកប្បកិរិយាជនជាប់ចោទផង។

ក្នុងករណីដែលពិនិត្យឃើញថា រឿងនេះ មានលក្ខណៈគ្រប់គ្រាន់ជាបទ ល្មើសព្រហ្មទណ្ឌហើយ រដ្ឋអាជ្ញាត្រូវធ្វើលិខិតចោទប្រកាន់ជនប្រព្រឹត្តបទល្មើស ដោយសំអាងមាត្រា ចំណុចច្បាប់ដែលតុលាការត្រូវផ្តន្ទាទោស។ បន្ទាប់មក ត្រូវរៀបចំសំណុំលិខិត ឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយ ធ្វើបញ្ជីសង់ ឈ្មោះសាក្សី និងអ្នកដែលមានទាក់ទងក្នុងសំណុំរឿង ដើម្បីឱ្យតុលាការ មានលទ្ធភាពកោះហៅនៅពេលជំនុំជំរះ រួចបញ្ជូនសំណុំរឿងទាំងមូលទៅតុលាការ តាមដីការអម។

ក្នុងករណីដែលសំណុំរឿង មានលក្ខណៈត្រឹមត្រូវ របាយការណ៍របស់ អង្គការស៊ើបអង្កេត មានលក្ខណៈត្រឹមត្រូវ គ្រប់ជ្រុងជ្រោយហើយ ប៉ុន្តែបទល្មើស ដែលត្រូវចោទប្រកាន់លើជនប្រព្រឹត្តល្មើស មានលក្ខណៈស្រាល មិនចាំបាច់ ធ្វើការចោទប្រកាន់ទោសដាក់ជូនតុលាការជំនុំជំរះ រដ្ឋអាជ្ញា ត្រូវធ្វើសេចក្តី សំរេចមិនចោទប្រកាន់ ដោយត្រូវបញ្ជាក់អំពីមូលហេតុឱ្យបានត្រឹមត្រូវបំផុត។

ម៉្យាងទៀត ប្រសិនបើ សំណុំរឿង ដែលអង្គការស៊ើបអង្កេត ស្នើសុំចោទប្រកាន់ ទៅលើជនណាមួយ រដ្ឋអាជ្ញាយល់ឃើញថា គ្មានធាតុគ្រប់គ្រាន់គួរឱ្យចោទប្រកាន់ចូលទៅក្នុងបទល្មើសអ្វីមួយនោះ រដ្ឋអាជ្ញាត្រូវធ្វើសេចក្តីសំរេចលើកលែង ចោទប្រកាន់ជននោះ ហើយត្រូវដោះលែងជាបន្ទាន់ ប្រសិនបើជននោះត្រូវ ចាប់ឃុំខ្លួន។ ឯទ្រព្យសម្បត្តិ ឬ វត្ថុតាងដែលរឹបអូស ប្រសិនបើមាន ត្រូវពិចារណាឱ្យហ្មត់ចត់ដូចបានលើកឡើងក្នុងចំណុច "ឃ" នៃផ្នែក "១"។

## II - អំពីនីតិវិធី និង របៀបធ្វើការងារ របស់តុលាការ មុនពេលជំនុំជំរះ និង នៅពេលជំនុំជំរះ

នៅពេលដែលរដ្ឋអាជ្ញា បញ្ជូនសំណុំរឿងមកដល់តុលាការហើយ ប្រធានតុលាការ ត្រូវចាត់ការ និង បំពេញភារកិច្ចជា ២ តំណាក់កាល ដូចតទៅ៖

### ១ - ដំណាក់កាលរៀបចំសំណុំរឿង

ក្នុងដំណាក់កាលនេះ ប្រធានតុលាការត្រូវ៖

ក - ចំពោះការជំនុំជំរះលើកទី ១ និង លើកចុងក្រោយបង្អស់

- ចាត់ចៅក្រមម្នាក់ ឱ្យធ្វើជាប្រធានក្រុមប្រឹក្សាជំនុំជំរះ។ ក្រោយពីបាន ពិនិត្យសំណុំរឿងសព្វគ្រប់ហើយ ចៅក្រម ដែលត្រូវចាត់តាំងឱ្យធ្វើជាប្រធាន ក្រុមប្រឹក្សាជំនុំជំរះ ត្រូវពិគ្រោះជាមួយនឹងរដ្ឋអាជ្ញា ដើម្បីឯកភាពគ្នាកំណត់ថ្ងៃជំនុំជំរះ។

- ជ្រើសរើសទីប្រឹក្សាប្រជាជនពីរនាក់ ពីក្នុងបញ្ជីរាយនាមទីប្រឹក្សាប្រជាជន ដែលរៀបចំ និង ផ្ញើមកពីគណៈកម្មាធិការរណសិរ្សសាមគ្គី កសាង ការពារមាតុភូមិ ខេត្ត ឬ ក្រុង។

- អញ្ជើញទីប្រឹក្សានោះ មកពិនិត្យសំណុំរឿង មុននឹងបើកសវនាការ។ ចំពោះរឿងណា ដែលប៉ះពាល់ដល់ផលប្រយោជន៍យុវជន នារី ឬ ជនជាតិភាគតិច គប្បីជ្រើសរើសទីប្រឹក្សាប្រជាជនដែលជាយុវជន នារី ឬ ជាជនជាតិ ភាគតិច។

- ក្នុងរឿងសំខាន់ ចាត់តាំងឱ្យមានអ្នកការពារម្នាក់ ឱ្យជួយការពារ ជនជាប់ចោទ បើជនជាប់ចោទគ្មានលទ្ធភាពនឹងពឹងអ្នកការពារឱ្យជួយកា ពារខ្លួនបាន។ អ្នកការពារ ក្រោយពីបានទទួលការចាត់តាំងភ្លាម មានសិទ្ធិ ពិនិត្យសំណុំរឿង ចម្លងលិខិតនានាក្នុងសំណុំរឿង និងចូលជួបជនជាប់ចោទនៅមន្ទីរឃុំឃាំង។

- ក្រុមប្រឹក្សាជំនុំជំរះ ដែលបានចាត់តាំងខាងលើនេះ ត្រូវពិនិត្យសំណុំរឿង ឱ្យបានល្អិតល្អន់ បើឃើញបញ្ជីរាយនាមអ្នកចូលរួមក្នុងសវនាកា ដែលបានធ្វើឡើងដោយរដ្ឋអាជ្ញា នៅមានខ្វះចន្លោះ ត្រូវចាត់ការបន្ថែម។ បើ ឃើញថា សំណុំរឿងនៅខ្វះចន្លោះ ត្រូវបញ្ជូនសំណុំរឿងទាំងមូលមកអយ្យការ ដើម្បីចាត់ការបំពេញ។

- ចេញដីកាសំរេចយកជនជាប់ចោទមកជំនុំជំរះចំពោះមុខតុលាការ។

- ចាត់តាំងលេខាធិការ - ក្រឡាបញ្ជីសវនាការ ២ រូប និង ចាត់តាំង លេខាធិការ-ក្រឡាបញ្ជី ឱ្យប្រគល់ដល់ជនជាប់ចោទផ្ទាល់ នូវលិខិតចោទប្រកាន់ ដីកាសំរេចយកជនជាប់ចោទមកជំនុំជំរះ ក្នុងករណីនេះ លេខាធិការ ក្រឡាបញ្ជីទទួលភារៈឱ្យដំណឹង ត្រូវធ្វើកំណត់ហេតុមួយអំពីការឲយដំណឹងនេះ ដោយឱ្យជនជាប់ចោទ ចុះហត្ថលេខា ឬ ផ្តិតមេដៃ ជាមួយផង ។

- ចេញលិខិតបង្គាប់ឱយនាំជនជាប់ចោទទៅតុលាការ។

- ចាត់ការធ្វើលិខិតអញ្ជើញដល់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងផ្នែករដ្ឋប្បវេណី សាក្សី អ្នកបកប្រែ និង ជនឯទៀត ដែលត្រូវមានវត្តមានក្នុងពេលសវនាការ។

- រៀបគំរោងសួរ និង វិធីសួរ ព្រមទាំងប្រុងប្រៀបដោះស្រាយលើផលវិបាកដែលអាចកើតបាន ជៀសវាងសំនួរដែលបានលក្ខណៈគំរាមកំហង មិនច្បាស់លាស់ សំនួរនៅមុខ ឬ សំនួរអត្តនោម័ត ដែលអាចឱយជនជាប់ចោទ ឆ្លៀតឱកាសឃោសនាប្រឆាំងនឹងបដិវត្តន៍។

**សំគាល់÷**

ក្រុមប្រឹក្សាជំនុំជំរះ និង រដ្ឋអាជ្ញា គប្បីប្រជុំគ្នា ដើម្បីពិភាក្សាលើបញ្ហា ដូចតទៅ៖

- វាយតម្លៃផ្នែកនយោបាយលើសំណុំរឿង

- គិតគូរធ្វើគំរោងលិខិតអញ្ជើញភ្ញៀវ ដែលត្រូវចូលមកស្តាប់សវនាការ

- រៀបចំកម្មវិធីសវនាការ

- ពិនិត្យលើផលវិបាក ដែលអាចនឹងកើតមាន។ ល ។

**ខ - ចំពោះការជំនុំជំរះសាឡើងវិញ**

- ចៅក្រមពីរនាក់ ដែលម្នាក់ជាប្រធាន

- ជ្រើសរើសទីប្រឹក្សាប្រជាជន ៣នាក់

- ចាត់តាំងអ្នកការពារម្នាក់ ឱ្យជួយការពារជនជាប់ចោទ។

ចៅក្រម និង ទីប្រឹក្សាប្រជាជន សុទ្ធតែអ្នកដែលមិនបានចូលរួមក្នុងការជំនុំជំរះលើកទី ១។

ក្នុងករណីដែលខ្វះចៅក្រម ប្រធានតុលាការ ត្រូវធ្វើសេចក្តីស្នើដល់រដ្ឋមន្ត្រី ក្រសួងយុត្តិធម៌ ដើម្បីតែងតាំងចៅក្រមម្នាក់ នៃតុលាការប្រជាជនក្រុង ឬ ខេត្ត ដែលនៅជិតខាង ដើម្បីឱ្យចូលរួមក្នុងការជំនុំជំរះសាឡើងវិញ។

ការពិនិត្យសំណុំរឿង របៀបជ្រើសរើសទីប្រឹក្សាប្រជាជន និង ការចាត់តាំង អ្នកការពារជនជាប់ចោទ ត្រូវអនុវត្តតាមសេចក្តីណែនាំ ដែលមានចែងក្នុងចំណុច "ក" ខាងលើ។

**២ - ដំណាក់កាលជំនុំជំរះ**

**ក - មុនបើកសវនាការ**

លេខាធិការ - ក្រឡាបញ្ជី មានភារកិច្ច ៖

- អានឱ្យបានពីរដង ឬ បីដង ហើយឱ្យខ្លាំងៗ ច្បាស់ៗ នូវបទបញ្ញាផ្ទៃក្នុង នៃបន្ទប់ជំនុំជំរះ

- ទាក់ទងជាមួយប្រធានកងការពារ ដើម្បីឱ្យដឹងអំពីចំនួនវត្តមាន នៃជនជាប់ចោទ និង មូលហេតុអវត្តមាន នៃជនជាប់ចោទ

- ពិនិត្យលើលិខិតអញ្ជើញនានា ដើម្បីឱ្យដឹងពីវត្តមាន នៃអ្នកចូលរួមផ្សេងទៀតក្នុងនីតិវិធី។

- សួរជនជាប់ចោទថា តើបានទទួលលិខិតចោទប្រកា ដីកាកោះឱ្យចូលខ្លួនហើយឬនៅ? ពីថ្ងៃណា ?

**ខ - ពេលសវនាការ**

**ដំណាក់កាលដំបូង**

- រដ្ឋអាជ្ញា និង អ្នកការពារ ចូលក្នុងបន្ទប់សវនាការ

- ស្នូរកណ្តឹង ៣ ដង ជាញ្ញាប្រាប់អំពីការចូលបន្ទប់សវនាការ នៃក្រុមប្រឹក្សាជំនុំជំរះ

- លេខាធិការ - ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ

- ក្រុមប្រឹក្សាជំនុំជំរះ ចូលកាន់កន្លែង ប្រធានសវនាការ អញ្ជើញសាធារណជនអង្គុយ រួចក្រុមប្រឹក្សាជំនុំជំរះ ក៏អង្គុយភ្លាមដែរ។

- ប្រធានប្រឹក្សាជំនុំជំរះ ក្រោកឈរ ប្រកាសបើកឱ្យកាសជំនុំជំរះ និង ប្រកាសកម្មវត្ថុនៃរឿងហេតុ រួចអង្គុយវិញ។

- ប្រធាន បង្គាប់ទេ លេខាធិការ – ក្រឡាបញ្ជី ឱ្យរាយការណ៍ជូន តុលាការអំពីវត្តមាន និង អវត្តមានជនជាប់ចោទ និង អ្នកចូលរួមផ្សេងទៀតក្នុងនីតិវិធី។ លេខាធិការ ក្រឡាបញ្ជី ក្រោកឈរ ហើយរាយការណ៍។

- ប្រធាន បង្គាប់ឱ្យប្រធានកងការពារ នាំជនជាប់ចោទចូលក្នុងបន្ទប់ជំនុំជំរះ។ ប្រធានកងការពាររាយការណ៍ជូនតុលាការអំពីវត្តមាន និងអវត្តមាននជនជាប់ចោទ។

- ប្រធាន បង្គាប់ឱ្យកងការពារទៅកាន់កន្លែង និង ឱ្យជនជាប់ចោទ អង្គុយចុះ។

- ប្រធាន ក្រោកឈរ ប្រកាសសមាសភាពតុលាការ រួចអង្គុយវិញ។

- ប្រធានបង្គាប់ឱ្យជនជាប់ចោទ មកឈរនៅមុខឈើរាងក្រចកសេះម្នាក់ម្តងៗ ហើយសួរសាវតារជាតិ: នាមត្រកូល និង ឈ្មោះពិតប្រាកដ ឈ្មោះប្រើក្រៅ, អាយុ ទីកន្លែង និង ថ្ងៃ ខែ ឆ្នាំកំណើត, របររកស៊ី ទីលំនៅមុនថ្ងៃចាប់ខ្លួន កំរិតវប្បធម៌ សាសនា ឈ្មោះប្តី ឬ ប្រពន្ធ ឈ្មោះឪពុក ឈ្មោះម្តាយ ចំនួនកូន ទោសពីមុន តើបានទទួលលិខិតចោទប្រកាន់ហើយឬនៅ? ពីថ្ងៃណា?

- ប្រធាន ប្រាប់ជនជាប់ចោទទាំងអស់ នូវសិទ្ធិរបស់ខ្លួនចំពោះមុខតុលាការ សិទ្ធិទទួលដំណឹងអំពីលិខិតចោទប្រកាន់ និង ដីកាកោះឱ្យចូលខ្លួន សិទ្ធិបង្ហញភ័ស្តុតាងនានា សំអាងសាក្សី និង ធ្វើសំណូមពរផ្សេងៗ សិទ្ធិ ប្តឹងសុំផ្លាស់ប្តូរសមាជិកក្រុមប្រឹក្សាជំនុំជំរះ ក្នុងករណីឃើញថា សមាជិករូបនោះ មានរឿងហេតុជាមួយខ្លួន, ជាមួយប្រពន្ធ ឬ ប្តី ឬក៍ ជាមួយឪពុក ម្តាយ បងប្អូនបង្កើតរបស់ខ្លួន ក្នុងពេលកន្លងមក សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬ ពឹង មេធាវី ឬ អ្នកដទៃណាមួយ ឱ្យជួយការពារខ្លួន សិទ្ធិនិយាយសំដីចុងក្រោយ បង្អស់មុនពេលតុលាការសំរេចសេចក្តី។

- ប្រធានសួរ តើមានប្តឹងសុំបដិសេធសមាជិកនៃក្រុមប្រឹក្សាជំនុំជំរះដែរឬទេ? បើគ្មានទេ បង្គាប់ឱ្យជនជាប់ចោទទៅកាន់កន្លែងវិញ

- ប្រធានៈ ហៅអ្នកចូលរួមឯទៀត ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី, សាក្សី ប្រសិនបើមាន ឱ្យមកបង្ហាញខ្លួន ម្នាក់ម្តងៗ ចំពោះមុខតុលាការ ហើយសួរអត្តសញ្ញាណ ដូចតទៅនេះ៖

នាមត្រកូល និង ឈ្មោះ, អាយុ, ទីកន្លែង និង ថ្ងៃ ខែ ឆ្នាំកំណើត, របររកស៊ី, ទីលំនៅសព្វថ្ងៃ, ឈ្មោះប្តី ឬ ប្រពន្ធ, ឈ្មោះឪពុកម្តាយ ហើយ សួរអ្នក ទាំងនោះ (លើកលែងតែសាក្សី) ថាតើមានប្តឹងសុំផ្លាស់ប្តូរសមាជិក នៃក្រុម ប្រឹក្សាជំនុំជំរះឬទេ ? បើគ្មានទេ បង្គាប់ឱយទៅកាន់កន្លែងវិញ។

- បើនៅពេលសវនាការ មានវត្តមានជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី និង សាក្សី ប្រធានសវនាកា ត្រូវប្រាប់ជនទាំងនោះ ឱយដឹងពីសិទ្ធិរបស់ខ្លួនចំពោះមុខតុលាការ។

**សិទ្ធិរបស់ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី**

- សិទ្ធិជូនភ័ស្តុតាងគ្រប់ប្រភេទ សិទ្ធិសុំឲយសងការខូចខាត សិទ្ធិសូ ឱយតុល ាការសួរទៅជនជាប់ចោទ វបញ្ហាដែលទាក់ទងនឹងរឿងរបស់ខ្លួន។

**សិទ្ធិរបស់អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី**

- សិទ្ធិឆ្លើយដោះសា និង បង្ហាញភ័ស្តុតាង

**សិទ្ធិ និង ភារកិច្ចរបស់សាក្សី**

- សិទ្ធិនិយាយតែអ្វីដែលខ្លួនបានឃើញ និង បានឮពិតប្រាកដក្នុងរឿងនោះ ហើយត្រូវទទួលខុសត្រូវចំពោះចម្លើយរបស់ខ្លួន។

- ប្រធានសវនាការ បង្គាប់ទៅសាក្សីទាំងអស់ឱ្យថយទៅនៅក្នុងកន្លែងមួយ ដែលបានរៀបចំសំរាប់សាក្សីទាំងនោះ ហើយដែលពុំអាចមើលឃើញ និងពុំអាចស្តាប់ឮ នូវអ្វីៗដែលមានធ្វើនៅក្នុងបន្ទប់ជំនុំជំរះ។ សាក្សីទាំងនេះអាច ចូលក្នុងបន្ទប់ជំនុំជំរះបានតែក្នុងករណីដែលប្រធានសវនាការត្រូវការសួរចម្លើយ។ ក្នុងពេលរង់ចាំនេះ សាក្សី មិនត្រូវប្រាស្រ័យទាក់ទងគ្នាទេ។ ពេលនោះត្រូវមានភ្នាក់ងារនគរបាលម្នាក់ អ្នកពិនិត្យមើល។

- ប្រធានសួរយោបល់រដ្ឋអាជ្ញា រួចអ្នកការពារ តើមានអ្វីបន្ថែមលើនីតិវិធីដែលបានប្រព្រឹត្តមកហើយ ឬទេ?។

### ៣-ដំណាក់កាលសួរដេញដោល , តទល់ និង បញ្ជាក់ភ័ស្តុតាង

- ប្រធានសវនការ បង្គាប់ឱ្យយជនជាប់ចោទទាំងអស់ មកឈរនៅពីមុខឈើរាំងក្រចកសេះ។

-ប្រធាន អញ្ជើញរដ្ឋអាជ្ញា អានលិខិតចោទប្រកាន់

- ប្រធាន សួរទៅរដ្ឋអាជ្ញា តើមានអ្វីបន្ថែមលើសេចក្តីចោទប្រកាន់នោះទៀតទេ? រួចប្រធាន បង្គាប់ឱ្យជនជាប់ចោទ ទៅកាន់កន្លែងវិញ។

- ប្រធាន បង្គាប់ជនជាប់ចោទម្នាក់ម្តងៗ ឱ្យមកឈរនៅពីមុខឈើខាង ក្រចកសេះ ហើយសួរជនជាប់ចោទ (ត្រូវយកជនជាប់ចោទណា ដែលចម្លើយ មានភាពស្មោះត្រង់ជាងគេមកសួរមុន)។

ក្នុងករណីចាំបាច់ ប្រធានសវនាការ អាចបង្គាប់ឱ្យយកជនជាប់ចោទម្នាក់ៗ មកសួរចម្លើយ ដោយកំបាំងមុខពីជនជាប់ចោទឯទៀតបាន។ ប៉ុន្តែ អ្នកការពារ ដែលទទួលភារៈការពារជនជាប់ចោទទាំងនេះ ត្រូវស្ថិតនៅក្នុងបន្ទប់ជំនុំជំរះ។

**សំគាល់**

១. នៅពេលដែលប្រធានសវនាកា កំពុងសួរដេញដោលជនជាប់ចោទ រដ្ឋអាជ្ញា អាចស្នើសុំប្រធានសវនការសួរជនជាប់ចោទបាន ក្នុងករណីដែល ត្រូវបំភ្លឺតុលាការត្រង់ចំណុចណាមួយ បើយល់ឃើញថាចាំបាច់។

២. បើជនជាប់ចោទ ប្រកែកពីបទចោទណាមួយ ប្រធានតុលាការ អាចសួរទល់ជាមួយសាក្សី ឬបង្គាប់ឱ្យលេខាធិការអានចម្លើយរបស់ជនជាប់ចោទ ដែលបានឆ្លើយសារភាពនៅចំពោះមុខអង្គការស៊ើបអង្កេត ដែលមាន នៅក្នុងសំណុំរឿង។

៣. ក្នុងពេលសួរដេញដោល ប្រធានសវនាការ ត្រូវចេះឆក់ឱកាស ដើម្បីយកវត្ថុតាងមកសំអាងលើការចោទប្រកាន់។

- ប្រធានសួរទៅទីប្រឹក្សាប្រជាជន បន្ទាប់មកសួររដ្ឋអាជ្ញា ក្រោយបង្អស់របស់រដ្ឋអាជ្ញាហើយ ប្រធានសវនាកា បង្គាប់ឱ្យជនជាប់ចោទទាំងអស់ អង្គុយវិញ។

ប្រធានអញ្ជើញអ្នកការពារជនជាប់ចោទ ឱ្យធ្វើសេចក្តីសន្និដ្ឋានការពារជនជាប់ចោទ។

- ប្រធាន ទុកពេលវេលាឱ្យរដ្ឋអាជ្ញា និងអ្នកការពារជនជាប់ចោទ ធ្វើការចោទឆ្លើយ និង បំភ្លឺតុលាការ ត្រូវត្រង់ចំណុចដែលយល់ថាចាំបាច់។

- ប្រធាន បង្គាប់ឱ្យជនជាប់ចោទ មកឈរនៅមុខឈើរាំងក្រចកសេះ ម្នាក់ម្តងៗ ហើយឱ្យនិយាយសំដីចុងក្រោយបង្អស់។

- ប្រធាន បង្គាប់ឱ្យកងការពារ នាំជូនជាប់ចោទទាំងអស់ ចេញពីបន្ទប់ ជំនុំជំរះ។

- ប្រធានប្រកាសថា ក្រុមប្រឹក្សាជំនុំជំរះ ត្រូវចូលក្នុងបន្ទប់ ដើម្បីពិភាក្សា។

**៥ - ដំណាក់កាលប្រកាសសាលក្រម**

- លេខាធិការ -ក្រឡាបញ្ជីសវនាការ អញ្ជើញសាធារណជនក្រោកឈរ។

- ប្រធានសវនាការ អញ្ជើញសាធារណជនអង្គុយ រួចប្រធាន អង្គុយដែរ។

- ប្រធាន បង្គាប់ឱ្យកងការពារ នាំជនជាប់ចោទទាំងអស់ ចូលក្នុងបន្ទប់ ជំនុំជំរះ។

- ប្រធាន បង្គាប់ឱ្យជនជាប់ចោទទាំងអស់ មកឈរនៅមុខឈើរាំងក្រចកសេះ។

- ប្រធាន ក្រោកឈរ ប្រកាសសាលក្រម ជាមួយគ្នានោះ លេខាធិការ, ក្រឡាបញ្ជី អញ្ជើញសាធារណជនក្រោកឈរ។

សួរអ្នកការពារ តើមានសំនួរអ្វីសួរជនជាប់ចោទទេ។

- ប្រធាន បង្គាប់ឱយជនជាប់ចោទទៅកាន់កន្លែងវិញ។

ការសួរដេញដោលលើជនជាប់ចោទឯទៀត ត្រូវធ្វើតាមនីតិវិធី ដូចខាងលើនេះដែរ។

បន្ទាប់ពីសួរចម្លើយជនជាប់ចោទ ប្រធាន ត្រូវសួរចម្លើយ ជនរងគ្រោះ ដើមបណ្តឹងរដ្ឋប្បវេណី និង អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី និងសាក្សី។ របៀបសួរចម្លើយសាក្សី ត្រូវសួរតាមរបៀបដូចតទៅ ៖

- សាក្សី របស់ជនរងគ្រោះ ឬ របស់ដើមបណ្តឹងរដ្ឋប្បវេណី

- សាក្សី របស់ជនជាប់ចោទ ឬ របស់អ្នកទទួលខុសត្រូវខាងរដ្ឋប្បវេណី។

របៀបសួរចម្លើយសាក្សី អាចនឹងផ្លាស់ប្តូរបាន ប្រសិនបើមានហេតុផលសំខាន់ជាចបាច់។

**៤ - ដំណាក់កាលចោទឆ្លើយរវាងរដ្ឋអាជ្ញា និងអ្នកការពារ**

បន្ទាប់ពីការសួរដេញដោលរួចស្រេចហើយ ប្រធានសវនាការ ស្នើអ្នកការពារជនរងគ្រោះ ឬដើម-បណ្តឹងរដ្ឋប្បវេណី ( ប្រសិនបើមាន) ឱ្យធ្វើ សេចក្តីសន្និដ្ឋាន។

- បន្ទាប់មកប្រធានសវនាការ បង្គាប់ឱ្យជនជាប់ចោទទាំងអស់មកឈរ នៅមុខឈើរាំងក្រចកសេះ ។

- ប្រធានស្នើឱ្យរដ្ឋអាជ្ញា ធ្វើសេចក្តីសន្និដ្ឋាន។ លុះចប់ការសន្និដ្ឋាន

- លុះអានចប់សមាសភាពតុលាការហើយ ប្រធាន អញ្ជើញសធារណជនអង្គុយ។

- ក្នុងពេលដែលតុលាការប្រកាស សំរេចសេចក្តី លេខាធិការ ក្រឡាបញ្ជី អញ្ជើញសាធារណជន ក្រោកឈរ។

- លុះប្រកាសសាលក្រមចប់ ប្រធានសវនាកា អញ្ជើញសាធារណជនអង្គុយ ប្រធាន អង្គុយដែរ។

- ប្រធានសវនាការ ប្រាប់ទៅគូភាគីថា បើមិនសុខចិត្តនឹងសាលក្រមនេះ ទេ អាចធ្វើពាក្យប្តឹងតវ៉ា ទៅក្រសួងយុត្តិធម៌បាន។

- ចំពោះសាលក្រមកាត់ទោសប្រហារជីវិត ប្រធានសវនាក ត្រូវប្រាប់ទណ្ឌិត អំពីសិទ្ធិសុំអនុគ្រោះទោសទៅក្រុមប្រឹក្សារដ្ឋ ក្នុងរយះ ៧ ថ្ងៃ គិត ពីថ្ងៃប្រកាសសាលក្រម។

- ប្រធាន បង្គាប់ឱ្យកងការពារ នាំជនជាប់ចោទ ចេញពីបន្ទប់ជំនុំជំរះ។

- ប្រសិនបើគ្មានសំណុំរឿងត្រូវជំនុំជំរះបន្តទៀតទេ ប្រធានត្រូវក្រោកឈរ ហើយប្រកាសបិទសវនាការ។

ក្រសួងយុត្តិធម៌សង្ឃឹមថា សេចក្តីណែនាំខាងលើនេះបានជាពន្លឺដល់សមមិត្តប្រធាន អនុប្រធានចៅក្រម និងរដ្ឋអាជ្ញា នៅគ្រប់តុលាការប្រជាជន ខេត្ត - ក្រុង ក្នុងការអនុវត្តន៍ភារកិច្ចរៀងៗខ្លួន មិនខាន។ ក្នុងករណីដែល ជួបនឹងការលំបាក គប្បីស្នើទៅក្រសួងយុត្តិធម៌។

ហត្ថលេខា និងត្រា

**អ៊ុក ប៊ុនឈឿន**

ចម្លងជូនៈ

- ក្រុមប្រឹក្សារដ្ឋ

-ក្រុមប្រឹក្សារដ្ឋមន្ត្រី

ដើម្បីជាពត៌មាន